# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤៧ សសរ**

## សេចក្តីសំរេច

## ស្តីពី

## ការប្រគល់សិទ្ធិ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១.-** ត្រូវបានប្រគល់សិទ្ធិជូន ឯកឧត្តម **ប្រាក់ សុខុន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល និងជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជា អ្នកសំរបសំរួលគំរោង ស្តីពីការពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ ជំនួសឯកឧត្តម **ស៊ុំ ម៉ានិត** ដែលត្រូវទៅព្យាបាលសុខភាពរយៈពេលវែង នៅប្រទេសបារាំង ។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សា អាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *កាលប្បវត្តិ-ឯកសារ*